AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com




CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com

# ច្បាប់ក្រមង៉ុយ

- ច្បាប់ល្បើកថ្មី
- ច្បាប់កេរកាលថ្មី
- សេចក្ដីរំលឹកដាស់តឿន
- ពាក្យកាព្យប្រដៅជនប្រុសស្រី

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



## អារម្ភកថា

ច្បាប់ក្រមង៉ុយនេះកាលបោះពុម្ពលើកមុនៗ ចែកចេញជាបីសៀវភៅ គឺសៀវភៅទី១ មានច្បាប់ល្បើកថ្មី និងកេរកាលថ្មី. ទី២ សេចក្ដីដាស់តឿន និងទី៣ពាក្យកាព្យប្រដៅជនប្រុសស្រី ។ នៅគ្រាបោះពុម្ពលើកទី៦នេះ ដោយនិយមតាមសេចក្ដីស្នើពីមជ្ឈដ្ឋានអ្នកសិក្សាជាច្រើននាក់ដែលសុំអោយយើងផ្ដុំគ្នាយកច្បាប់នេះមករួមគ្នាជាសៀវភៅមួយ ត្បិតទុកអោយនៅដោយឡែកៗជាកូនសៀវភៅតូចៗនោះនាំអោយរប៉ាត់រប៉ាយ ពិបាកថែរទាំ ។ យោបល់នេះត្រឹមត្រូវណាស់ ទើបយើងសម្រេចប្រមូលផ្ដុំបានជាសៀវភៅមួយនេះឡើង ។

ចំពោះពាក្យពេចន៍ កាព្យឃ្លោងទាំងអស់នៅក្នុងច្បាប់ទាំងប៉ុន្មាននេះ យើងគ្មានប៉ះពាល់កែប្រែសោះឡើយ សម្រួលតែរបៀបតម្រៀបឃ្លាល្បះអោយមានលំនាំទៅតាមបែបកាព្យត្រឹមត្រូវប៉ុណ្ណោះ ។

គោលបំណងធំរបស់យើងខ្ញុំមួយទៀត គឺការចង់រក្សាស្នាដៃដ៏មានតម្លៃនៃលោកតាកវី **ភិរម្យង៉ុយ ឬក្រមង៉ុយ** ព្រោះពាក្យសំដីរបស់លោកក្នុងនេះទាំងអស់សុទ្ធតែមានន័យទូលំទូលាយ ហើយប្រកបដោយខ្លឹមសារល្អណាស់មិនចេះហួសសម័យកាលនោះផង តាំងពីគ្រាលោកសរសេររហូតសព្វថ្ងៃនៅតែមានន័យត្រូវគួរនិងធ្វើគតិទូន្មានខ្លួនបាន ។

ឆ្លៀតឱកាសនេះ ពុទ្ធសាសនបណ្ឌិតសុំសម្ដែងគារវកិច្ចដ៏ជ្រាលជ្រៅចំពោះវិញ្ញាណក្ខន្ធនៃលោកកវីដ៏ឆ្នើមនេះផង ។

ភ្នំពេញ ខែ សីហា ឆ្នាំ ១៩៧២

**ពុទ្ធសាសនបណ្ឌិត្យ**

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



# ច្បាប់ល្បើកថ្មី

អ្នកព្រះភិរម្យ ភាសាអ៊ូខ្ញុំ បង្គំនឹកគុណ
ព្រះពុទ្ធព្រះធម៌ ព្រះសង្ឃជាមុន គុណគាប់មហាធ្ងន់
មាតាបិតា ។

ឧបជ្ឈាយ៍ជាធំ កាលចាប់ដៃខ្ញុំ អោយធម៌កេសា
អនុសាវ៍ន ព្រះកម្មវាចា គុណធម៌អក្ខរា
ទាំងសាមសិបបី ។

ខែបែត្រឆ្នាំច ចត្វាស័កក កគិតកាព្យថ្មី
លើកច្បាប់ប្រដៅ កូនចៅប្រុសស្រី តូចក្តីធំក្តី
ចូរស្តាប់គ្រប់គ្នា ។

ត្បិតមនុស្សឥឡូវ យកខុសជាត្រូវ យកឆ្គួតធ្វើជា
អំពើអាក្រក់ ឡិឡក់លីលា ព្រហើនពានពារ
អាងមាសអាងប្រាក់ ។

អាងព្រើលអាងប្រាជ្ញ អាងកោងអាងកាច អាងកាប់អាងចាក់
អាងជើងអាងដៃ អាងវាយអាងធាក់ អាងគុកច្រវាក់
អាងម៉ាស៊ីនកាត់ក ។

អាងសុទ្ធតែខុស កូនអើយចាំចុះ អាងនោះមិនល្អ
អ្នកគិតអោយល្អិត ដ្បិតស្រុកលោកក្រ ប្រមាណដំណ
តទៀតទៅមុខ ។

សាសនានៅឆ្ងាយ លែងបានសប្បាយ មានតែកើតទុក្ខ
កើតទាន់លោកិយ ព្វតែទំនុក ដំណែលអាពុក
ចូរចាំគ្រប់គ្នា ។

អ្នកជឿពាក្យចាស់ ជឿចាំអោយណាស់ កុំធ្វើប៉ះពា
អ្នកហ៊ានស្បែកដាច អ្នកខ្លាចស្បែកជា មនុស្សប៉ោបៀ
កុំយកខ្លួនបៀត ។

ឃើញឬកគេល្អ ទោះបីមានក្រ យកគេធ្វើញាតិ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



គួររាប់អ្នកក្រៅ ផៅអ្នកឯទៀត រាប់រើសមាយាទ
សុចរិតត្រឹមត្រូវ ។

រៀនបទរៀនបាទ កុំកោងហួសខ្នាត កុំភ្លាត់ហួសផ្លូវ
កុំភ្លើនហួសម៉ែ កុំប្រែហួសឪ ឃើញចាស់សក់ស្កូវ
កុំសូវមើលងាយ ។

បន្ទន់អាត្មា ខ្លាចមេខ្លាចបា ខ្លាចតាខ្លាចយាយ
បំរើមហាក្សត្រ ប្រយ័ត្នស្តេចទាយ ពាក្យពិតទំនាយ
រលាយកេរ្តិ៍ឈ្មោះ ។

ពាក្យស្តេចពាក្យគ្រូ មានប្រែមានជូរ កម្រពិរោះ
ជូនទាយអោយទាប ជូនទាយអោយខ្ពស់ ទាយអោយស័ក្តិយស
ទាយចុះកុំខឹង ។

បម្រើមើលភេទ ចំណាំព្រះនេត្រ ហេតុខ្លួនអោយដឹង
ខ្លួនខ្ជិលហៃព្រើល លោកមើលសំឡឹង សំឡក់អោយប្រឹង
ខំប្រិតរៀនសូត្រ ។

បម្រើមើលពុត ប្រាជ្ញាអោយមុត ស្មារតីអោយមាន
បើខ្មៅអោយប្រាជ្ញ បើខ្លាចអោយហ៊ាន ចង់បានរបៀប
កុំអៀនកុំខ្មាស ។

ពុកលោកជាធំ ជ្រងោប៉ុនភ្នំ ឯងមើលមិនច្បាស់
បម្រើលោកណា លោកហ្នឹងជាម្ចាស់ លោកស្អប់អ្វីណាស់
ប្រាសចោលអោយឆ្ងាយ ។

កុំឈមឈរជិត កុំយកធ្វើមិត ភ្លាត់ខ្លួនអន្តរាយ
លើប្រពន្ធកូន បងប្អូនចៅហ្វាយ អាពុកឬម្តាយ
ឱនកាយប្រតិបត្តិ ។

អ្នកកុំមើលងាយ ឃើញគេរីករាយ ព្រួញខ្លួនប្រយ័ត្ន
ត្រកូលញាតិផៅ កូនចៅមហាក្សត្រ ស្មើថ្លើមប្រមាត់
ប្រមាថមិនបាន ។

ទោះអ្នកដទៃ អ្នកព្រៀងអ្នកព្រៃ ដែលលោករាប់អាន
កុំថាតែមនុស្ស ទោះសត្វតិរច្ឆាន ឯងស្អប់ប៉ុន្មាន
កុំហ៊ានប្រមាថ ។

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

របស់ឬទ្រព្យ ដែលចោរសំអប់ កុំបាច់សំអាត
ទ្រព្យណាសំឡាញ់ អញអស់ឱហាត ចូរចៅសង្ហាត
ជួយថែរក្សា ។

កុំជិះកុំជាន់ ស្មៅផ្ទីអាចម៍មាន់ ពាក្យចាស់ឧបមា
បុរាណហៅថ្មី ពីរបីប្រការ កុំស៊ីត្រង់ណា
ជុះដាក់ត្រង់ហ្នឹង ។

សាច់សារលោហិត កុំផ្ដួលផ្ដេកពិត ផ្ដួចទោសកើតប្ដឹង
អាពុកផ្ដែផ្ដាំ ចូរចាំចេះថ្លឹង សាចថ្លើមស្ងួតឆ្អឹង
និងស្បែកខាងក្រៅ ។

សាច់ស្ងួតក្នុងខ្លួន ទុកស្មើបងប្អូន ប្រពន្ធកូនចៅ
សរសៃនិងស្បែក ចែកញាតិជាផៅ ខ្ញុំស្រីខាងក្រៅ
ជាស្មៅអាចម៍មាន់ ។

ស្រីខ្ញុំកំដរ បើឃើញរូបល្អ កុំលលួកលាន់
កុំលបលួចលេង ក្រែងម្ចាស់គេទាន់ កុំភប់កុំភាន់
អាប់អន់អាត្មា ។

បើអ្នកមានយស មានស័ក្តិខ្ពង់ខ្ពស់ គាប់នឹងរាជការ
ធ្វើធំធ្វើថី មន្ត្រីមានត្រា ព្រះហ្លួងឧកញ៉ា
សាលាកុង្សីយ៍ ។

ចេះច្បាប់បារាំង កុំភ្លេចសច្ចំ កត្តញ្ញូខន្តី
កុំឆ្មើងហួសមាឌ ភ្លេចញាតិប្រុសស្រី ជំនុំកាត់ក្ដី
យកឧបេក្ខា ។

កុំកាន់សីហលោ កុំកាន់លោភោ ទោសោមោហោ
កុំជក់អាភៀន កុំឃ្លានផឹកស្រា កុំស្អប់ខាងណា
សច្ចាយកត្រង់ ។

លួងលោមពិសោធន៍ កុំឆបញ្ឆោត បញ្ចូលអោយបង់
អោយបែកអោយបាក់ ពាក្យសត្យពាក្យសង្ឃ កូនអើយផ្ចិតផ្ចង់
តម្រង់ស្មារតី ។

កុំភ្លើនភ្លេចប្រាក់ កុំភ្លើភ្លាត់សក្តិ ធ្លាក់ទៅអវិចី
កាន់ធមិទសពិធ វិតឡើងរាសី គាប់ពីលោកិយ

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ដល់បរលោកនាយ ។

អ្នកក្ដីជាភ្លើង កុំកាត់កាន់ជើង អ្នកម្ខាងមើលងាយ
ចៅក្រមជាទឹក រំលួករំលាយ កុំដេកុំវាយ
បង្គំនាំខុស ។

ចោរខូចលួចប្លន់ រឺចោរស្ម័គ្រស្មន់ តណ្ហាប្រុសស្រី
កុំស្អប់ខាងណេះ បញ្ជេះខាងណោះ លួងលោមបញ្ចុះ
បញ្ចូលចិត្តក្ដី ។

កុំដុតអោយក្ដៅ បើឃើញគ្នាខ្លៅ ប្រាជ្ញាគ្នាខ្ចី
កុំឃ្លានប្រាក់ប្រុស បន្ទុះខាងស្រី បើកាន់ច្បាប់ថ្មី
កុំចោលច្បាប់ចាស់ ។

កុំជៀលអ្នកស្រែ ត្រកូលឯងខ្មែរ កុំប្រែក្រឡាស់
ក្រឡេកឃើញគុណ ទន់ខ្លួនសំពះ កុំធ្វើអ្នកណាស់
កុំត្មេះអ្នកក្រ ។

អ្នកកុំភ្លេចគុណ គ្រូលេខនព្វន្ត គ្រូសូត្រអក្សរ
កុំចាប់ទាញដៃ គុំនាប់ងក់ក កុំជដែកគត
ស្មើមិត្តសំឡាញ់ ។

វាស្រ្តរត់ចូលជ្រក សួរសាកទៅមក កុំអើឯងអញ
ពាក្យពុំពិរោះ គេកើតមួក្កាញ់ គេជៀលផ្ចាលផ្ចាញ់
អន្តរាយកេរ្តិ៍ ។

កុំឆ្មើងអាងបុណ្យ ស្រដីអោយទន់ ពោលពាក្យពីរោះ
ខ្លួនអ្នកនឹងថ្កើង នឹងឡើងសក្តិយស កុំឆ្លៀតនាំឈ្លោះ
ញុះញង់អ្នកធំ ។

កុំស្អប់អ្នកតូច បើឃើញគ្នាខូច គួរគិតប្រមុំ
ទោសគ្នាតិចតួច ផ្ដួចឡើងជាធំ ផ្សែងពួតជាដុំ
ផ្ដុំឆេះជាភ្លើង ។

កុំភ្លើនភ្លេចខ្លួន ចេះសាសន៍ចិនយួន កុំចោលខ្មែរយើង
កុំធ្វើក្រអឺត កុំពើតកុំពើង កុំពាក់ស្បែកជើង
ចូលវត្តលោកសង្ឃ ។

ដោះមួកដាក់ឆ័ត្រ ឱនកាយប្រតិបត្តិ លំអុតឱនអង្គ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

កុំស៊ីតាមឃ្លាន កុំហ៊ានតាមចង់ កាន់ច្បាប់ស្រុកប្រេង្ស៍
កុំបង់សាសនា ។

កុំចង់ថ្កើងពេក កុំលើកដំណេក ហួសមេហួសបា
តែងខ្លួនអោយល្មម មើលពូជពង្សា សង្វេបនិដ្ឋិតា
រឿងផ្តាប់បុណ្យសក្តិ ។

បើទៅជារាស្ត្រ ប្រាជ្ញាវៃឈ្លាស គួរវាសឆ្លកឆ្លាក់
អោយឆ្លៀតរកពុន បើធូន់សុំដាក់ ខំរកមាសប្រាក់
អោយគ្រាន់ទាន់ចាយ ។

រាជបារាំងសែស កូនកុំប្រហែស កុំថ្មមរូបកាយ
ដើរគិតដេកគិត ជួញជិតជួញឆ្ងាយ បើចង់សប្បាយ
ស្រេចនៅមានទ្រព្យ ។

រាជហ្លួងពីមុន រកស៊ីរកពុន មានក្រតាមភ័ព្វ
រាជ្យលោកឥឡូវ ត្រូវខំអោយញាប់ តែខ្ជិលច្រើនជាប់
ខ្ទោះជើងខ្ទោះដៃ ។

តាំងពីឆ្នាំច ចាំជាដំណ ទំនិញឡើងថ្លៃ
ចងក្បិនអោយតឹង ប្រឹងកុំសំចៃ សញ្ជឹងយប់ថ្ងៃ
កុំអោយក្រខ្សត់ ។

បើចង់ស្រួលខ្លួន រៀនសូត្រអោយមួន អោយមាំអោយស្ទាត់
កុំចេះស្ទាក់ស្ទើរ ល្ងីល្ងើឥតបទ បើចេះប្រាកដ
ប្រាក់រត់តាមហៅ ។

កុំថ្មមកម្លាំង កាប់ជីកចូកចាំង កុំថារងារក្តៅ
រៀនអ្វីអោយឆ្អិន កុំអោយខ្លោចឆៅ កុំដេកតែខ្លៅ
ក្រក្រៅសណ្តាប់ ។

បើល្ងង់អោយចេះ រករៀនតម្រិះ រិះរកតម្រាប់
ឥន្ទ្រីយឆ្វេងស្តាំ កុំចាំគេប្រាប់ រៀនស្តីរៀនស្តាប់
រៀនមើលអោយស្ដែង ។

កើតមកជាមនុស្ស ទាំងស្រីទាំងប្រុស មិនដែលចេះឯង
បើក្រអោយមាន វិញ្ញាណចេះក្រែង គិតគ្រប់កន្លែង
កុំដេកតែក្រ ។

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



កុំប្លន់កុំលួច កុំខ្ជិលកុំខូច កុហកឆ្វវឆ
បោកប្រាស់យកប្រាក់ ច្រវ៉ាក់ជាប់ក កាន់មារយាទល្អ
សុចរិតត្រឹមត្រូវ ។

កូនអើយរកស៊ី កកាយធរណី ធ្វើស្រែយកស្រូវ
កុំតាមអ្នកណា បាតាមតែឪ លើកភ្លឺជិតផ្លូវ
កុំស្រាស់បន្លា ។

គេដើយប់ថ្ងៃ មុតជើងមុតដៃ ដឹងចៀសទៅណា
ចៀសចុះជាន់ស្រូវ ហើយជេរផ្ដាសា កូនម្ដាយអាណា
ស្រាស់ដើរមិនរួច ។

កុំយកគល់ឈើ ទៅដាក់ពីលើ ទោះធំទោះតូច
ជំពប់ជើងគេ គេថាឯងខូច ជេរជៀលដល់ពូជ
ប្រដូចមេបា ។

លើកភ្លឺអោយធំ បង្ហាប់អោយមាំ គាប់ភ្នែកទេវតា
ស្មើបានសង់ស្ពាន និងមានផល្លា កើតសាធុការ
អាយុយឺនវែង ។

កូនអើយធរណី បើតាមគម្ពីរ ដែលលោកសម្ដែង
កុំចង់បានធំ ប្រមុំឆ្វៀលឆ្វេង កុំលើកដីឯង
លប់ដាក់ស្រែគេ ។

អំពើអាក្រក់ មួយចំរៀកសក់ ធ្លាក់ទៅនិរយេ
បច្ចុប្បន្នលោកិយ កើតក្ដីវ៉ាយជេរ មិនដែលសុខទេ
ព្រោះដីមួយហត្ថ ។

កុំជួញចង់ទាស់ ខូចខាតរបស់ អស់ទ្រព្យសម្បត្តិ
ចង់គង់ប្រយោជន៍ អោយចេះប្រយ័ត្ន ពាក្យឪមួយមាត់
អោយគិតមួយម៉ោង ។

សំអាតផ្ចិតផ្ចង់ លើកភ្លឺអោយត្រង់ កុំលើកអោយកោង
អ្នកកុំប្រហែស ក្រែងមានប្រហោង លើកមើលទំនង
ទំនាបទឹកហូរ ។

ចំនួនទឹកស្ទឹង ទឹកព្រែកទឹកបឹង ទឹកវាលទឹកអូរ
អ្នកលើលិចស្រូវ ត្រូវបើកបង្ហូរ អ្នកក្រោមកុំថ្ងូរ

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



| | | |
|---|---|---|
| | បន្ទរហួសទៅ ។ | |
| រាំងរឹងយប់ថ្ងៃ | ឆាប់លើកឆាប់ទប់ | កុំអោយបាក់ជ្រៅ |
| កត្តិកចេញខ្យល់ | តម្កល់ទឹកនៅ | បើចង់បានស្រូវ |
| | បាននៅត្រឹមថៃ ។ | |
| កុំយកគ្រាប់ត្នោត | ទៅដាំទៅដោត | នៅលើភ្លឺស្រែ |
| ចិត្តគិតប្រមាណ | ចង់បានផ្កាផ្លែ | ដាំដុះបង្ហែ |
| | បង្ហិនខ្លួនឯង ។ | |
| ដល់ត្នោតឡើងគល់ | ឡើងកើតនាំខ្វល់ | ធាងលូតឡើងវែង |
| ភ្ជួររាស់ជាប់នឹម | ក្របីជាប់ស្នែង | ទទើសទទែង |
| | ភ្ជួរឆ្វេងមិនត្រូវ ។ | |
| ដល់ត្នោតវាធំ | មានស្លឹកវាទុំ | វាជ្រុះក្នុងស្រូវ |
| ស្រែឆ្ងាយពីផ្ទះ | ឃ្លាតណាស់ពីផ្លូវ | ទំរាំតែទៅ |
| | រលួយស្រូវអស់ ។ | |
| កូនអើយកុំឆោត | បើចង់បានត្នោត | ដាំដោយក្បៀនកោះ |
| ដីទួលចំការ | ឯណាចន្លោះ | ដាំជាររបោះ |
| | ជាយជួររបង ។ | |
| របៀបចំការ | ថែទាំរក្សា | យូរៗស្រាល់ម្តង |
| ស្រាស់អោយត្រូវជួរ | មើលគួរសមផង | កុំបើកមុជឆ្លង |
| | ទៅស្រាស់ខាងក្រៅ ។ | |
| មិនគាប់ប្រសើរ | របងវាដើរ | អ្នកម្ខាងវាក្តៅ |
| កើតក្តីកើតក្តាំ | អស់ខោអស់អាវ | ខឹងអស់ញាតិផៅ |
| | ពីព្រោះចំការ ។ | |
| មួយទៀតរបង | ជិតផ្លូវអ្នកផង | គេទៅណាៗ |
| ធ្វើអោយទូលាយ | កុំវាយបន្លា | កាប់ឆ្កើសទាត់ផ្ការ |
| | អោយឆ្ងាយពីផ្លូវ ។ | |
| កុំធ្វើចង្អៀត | ក្រែងយប់អាចោរ | ខ្លះមកខ្លះទៅ |
| ចៀសគ្នាមិនរួច | បើកបរកាត់ស្រូវ | ដើរម្តាយតាមផ្លូវ |
| | រហូតដល់ផ្ទះ ។ | |
| កូនអើយអ្នកចាំ | អ្នកកុំចងកម្ម | មានពារច្រើនណាស់ |

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ជាតិក្រោយខ្វាក់ខ្វិន កខ្វេះកខ្វាស សូវចោលដីខ្លះ
មិនខាតប៉ុន្មាន ។

កុំខ្លាចតែក្រ ធ្វើឫកមិនល្អ ច្រើនកើតវឱស្ថាន
រអែករអោក បាត់ញាតិសន្តាន ឥតគេរាប់អាន
មានតែគេស្អប់ ។

កាន់ឫកអោយខ្ពស់ អោយខ្ពើមពាក្យឈ្លោះ ទើបបានជាគាប់
យកឆោតជាក់ខ្លួន ច្រើនមានគេរាប់ បើខ្លួនឥតទ្រព្យ
កុំធ្លាប់ហ៊ានខ្ចី ។

គ្រប់ការសារពើរ ចង្អេរកញ្ជើ កន្តាំងតៅល្អី
រនាស់រទេះ គោសេះក្របី បើបានជាខ្ចី
ខ្ចីប្រាក់គេទិញ ។

យកមករកស៊ី ខែមួយខែពីរ សងប្រាក់គេវិញ
របស់បានយើង ជាជើងជួញចេញ ឯទ្រព្យនោះមិញ
ពេញជាទ្រព្យឯង ។

កុំខ្ចីគេប្រើ តែមួយដំណើរ មិនយូរអង្វែង
ជូនជាបាក់បែក ជដែកទាស់ទែង សងគេមិនលែង
ចាស់ផ្លាស់ជាថ្មី ។

កើតមកជាប្រុស គិតអោយសព្វសុស កុំអោយសល់អ្វី
បួសរៀនធម៌អាថ៌ សាស្រ្តាបាលី បរលោកលោកិយ
កុំបីចន្លោះ ។

សឹកមករកស៊ី កកាយធរណី ធ្វើជាគ្រហស្ថ
កុហាកជឿបុល បំណុលរុំកោះ ច្រើនគេដាក់ខ្នោះ
អស់ស្រែចំការ ។

ធ្វើរាស្រ្តរកស៊ី ចិញ្ចឹមគោញី ថែទាំព្យាបាល
ក្រហេតុពីខ្ជិល មានឈ្មិតឧស្សាហ៍ អ្នកមានប្រាជ្ញា
មិនស្មើគំនិត ។

កំណើតសំណាង សំណូមពរអាង កកើតពីគិត
ពីកាលជាតិមុន បុណ្យព្រេងអតីត កើតរួមគំនិត
ទើបកើតសំណាង ។

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ឯមនុស្សសំណល់ ល្ងង់ល្ងើងឆ្គល់ ទាសទែងក្មេងក្មាង
ដប់ឆ្នាំនេះហើយ ប្រកាន់ម្យ៉ាងៗ ខ្លះអួតសំណាង
ខ្លះអាងគំនិត ។

កូនចៅប្រុសស្រី រកប្រពន្ធប្តី អោយរកស្រុកជិត
បើរកស្រុកឆ្ងាយ អោយម្តាយពិនិត្យ អោយត្រឹមត្រូវពិត
ពូជពង្សាវតា ។

កូនអើយអ្នកចាំ កុំជឿខែឆ្នាំ កុំជឿតម្រា
ពាក្យក្បួនតម្រាយ កើតពីមនុស្សចារ ពីដូនពីតា
ចារតាមសម្គាល់ ។

អ្នកជឿតែពូជ អម្បូរធ្លាប់ខូច វាខូចរៀងរាល់
ពូជមានវាមាន ពូជទាល់វាទាល់ កុសលអកុសល
យើងមើលមិនជាក់ ។

ប្រពន្ធនិងប្តី អាយុវែងខ្លី យើងមើលឃើញច្បាស់
កុំយកពូជល្បែង ពូជភ្លេងអារក្ខ បើម៉ែបង់ប្រាក់
រកអាយុវែង ។

អម្បូរពូជពង្ស ត្រកូលធ្លាប់ខូច វាខូចមិនល្វែង
ពូជចោរស្រីៗ យកប្តីចិត្តឯង មិនគិតកោតក្រែង
ខ្លាចចិត្តមេបា ។

កូនចៅស្រីៗ បើនឹងយកប្តី អោយមើលកិរិយា
មួយភ្លេងអារក្ស មួយអ្នកបាណា មួយអ្នកផឹកស្រា
មួយអ្នកចង់ស្រី ។

ពួកអ្នកក្រម៉ាច់ លេងផោមលេងអាចម៍ អាយុច្រើនខ្លី
ប្រកាច់ដាច់លក្ខណ៍ ជាន់អារក្ខព្រៃ មួយគឺមន្ត្រី
ធ្វើក្រមជំទប់ ។

ជំទយតែដើរ មេស្រុកគេប្រើ ទាំងថ្ងៃទាំងយប់
មានមួកខ្នុះឆ័ត្រ កម្រមានគ្រប់ មួយទៀតកំភប់
ជួញប្រាំប្រការ ។

ប្រាកដជាខុស លក់សត្វទាំងរស់ មិនចេះអនិច្ចារ
សព្វសត្វអ្វីៗ បក្សីបក្សា ព្រាត់មេព្រាត់បា

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ទេវតាលោកលក់ ។

លោកិយនេះខ្សត់ យមបាលគេកត់ នៅស្ថាននរក
មួយហួយអាប៉ោង ប៉ោបៀគ្រប់មុខ កូនអើយចាំទុក
ក្រគ្រប់ប្រាំបី ។

ឯអ្នកទាំងអស់ រកស៊ីម៉េះម៉ស់ ច្រើនជាងស្រី១
ប្រាជ្ញានោះវែង គំនិតនោះខ្លី ប្រពន្ធជេរស្ដី
អាងឈ្មោះបំពាន ។

នេះពូជអ្នកក្រ រស់ទាំងត្រដរ ទាំងអត់ទាំងឃ្លាន
ធ្វើគុណនិងគេ រកគេសងគ្មាន ហេតុនេះកុំរៀន
ទាំងប្រាំបីផ្លូវ ។

យ៉ាងអ្នកនេសាទ មិនដែលសង្វាត ធ្វើស្រែបានស្រូវ
ប្រព្រឹត្តសាងកម្ម ប្រចាំរដូវ វង្វេងខុសផ្លូវ
ព្យាយាមសម្លាប់ ។

អន្ទាក់ជុងកុក អង្រុតឈ្នាងឆ្នក់ គ្រប់គ្រឿងប្រដាប់
ថ្លុកបៀត្រពាំង ទប់បាំងបាចចាប់ ចោលស្រូវកណ្ដាប់
កណ្ដៀវកាត់អស់ ។

កំពប់ខ្ជាត់ខ្ជាយ ខូចខាតអន្តរាយ មិនស្ដាយស្រណោះ
យប់រវល់ប្របក់ ចង់បានត្រីរស់ ខែភ្លឺរវល់ឆ្លុះ
ដើរដេញសំពោច ។

រក់តែសប្បាយ ដើរដេញទន្សាយ ដើរចងសន្ទូច
អំពើអស់នោះ ច្រើនខ្វះស្រវពូជ ធ្វើបានតិចតួច
អាងជឿគេស៊ី ។

កូនអើយបំណុល ចងការជឿបុល មួយឡើងជាពីរ
អ្នកភ្លេងអារក្ខ ច្រើនទឹមគោញី មួយឡើងជាពីរ
ធ្វើសោះតែខាន ។

ថ្ងៃដេករកភ្នាក់ យប់លៀងអារក្ខ ឈើឆ្កាលសន្ទាន
គេស្ដីគេពឹង នឹងឈប់ពុំបាន គេរករាប់អាន
កាលមានធុរៈ ។

ផ្លុំប៉ីកួតទ្រ ស្រែកច្រៀងវាយស្គរ មិនបានលុយកាក់

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



| | | |
|---|---|---|
| ឯងពឹងគេវិញ | គេគ្មានជំពាក់ | ពឹងបានម្នាក់ៗ |
| | ដោយសារអោយថ្លៃ ។ | |
| ឡើងត្នោតភ្ជួរស្រែ | កម្រទាន់គេ | ដ្បិតដេកដល់ថ្ងៃ |
| ច្រូតកាត់ចង់ឆាប់ | ជួលគេពេញថ្លៃ | ចំណេះចង្រៃ |
| | នាំខាតធ្វើការ ។ | |
| ឯងខ្មោចអារក្ខ | ស្លាប់ដល់រស់ម្នាក់ | ថ្វាយចេកថ្វាយស្រា |
| សំពះនឹកគុណ | ខ្មោចប្រេតដូនតា | មិនដែលអ្នកណា |
| | នឹកគុណអ្នកភ្លេង ។ | |
| ឯអ្នកប្រមឹក | ប្រមូលកូនផឹក | ធ្វើភឿននឹងក្មេង |
| សមជីច្រើនតឹង | ស្រវឹងវង្វេង | ជំហរអ្នកភ្លេង |
| | មិនចេះក្រខ្សត់ ។ | |
| អួតទាំងបំពាន | ផឹកម្ល៉េះលុយមាន | ផឹកម្ល៉េះលុយអត់ |
| ឯងចេះតែកិន | ចិនចេះតែកត់ | ផឹកដល់កំណត់ |
| | យកស្រែបញ្ចាំ ។ | |
| សល់ថ្នាលមួយពីរ | វាយគោស្មោរស៊ី | មិនគិតខ្លាចកម្ម |
| ផឹកជ្រុលហួសល្បត់ | អត់បាយរាល់ឆ្នាំ | អស់ស្រែបញ្ចាំ |
| | បញ្ចាំកូនទៀត ។ | |
| កំណើតផឹកស្រា | ផឹកផុតមេត្តា | ផឹកជ្រុលហួសមាឌ |
| អ្នកមួយផឹកស្ទើរ | ល្ងីល្ងើចេះឆ្លៀត | ម៉្យាងផឹកផុតមារយាទ |
| | ច្រើននៅខ្ញុំចិន ។ | |
| រែកទឹកពុះឧស | វាទុញវាតុះ | ចាក់កែវផឹកសិន |
| ស្ទូរែកខំអត់ | សំពត់ខើចក្បិន | ទំរាំបាយឆ្អិន |
| | ចិនដួសហៅស៊ី ។ | |
| ឆ្នាញ់តែម្នាក់ឯង | ឆ្អែតហើយខំស្វែង | ខំលើកខំលី |
| ដងទឹកស្រោចគ្រប់ | ស្រោចខ្ទឹមម្ទេសជីរ | ខ្ញុំចិនម៉្លេះពីរ |
| | វិលទៅរវាំងផ្ទះ ។ | |
| ឯអ្នកចង់ស្រី | ប្រពន្ធពីរបី | ថាឯងអ្នកណា |
| គន់ឯសំពត់ | តែមួយបន្លាស់ | ពាក់អាវបំណាស់ |
| | កម្រមានថ្មី ។ | |

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ផ្ទះលេចវាយល្វឹង ជញ្ជាំងឆងហ៊ីង ស្លាធ័របាយសី
ខូចប្រេងក្រមួន ម្លូស្លាបារី កំឡោះពីបីរ
ចោមរោមរៀនស្នេហ៍ ។

រៀនស្អាលរៀនស្ទិទ្ធ កើតក្តីពីក្តិត ព្រួយចិត្តឪម៉ែ
កូនអើយប្រពន្ធ អាងមន្តពូកែ ត្រូវគុកដប់ខែ
អស់ស្រែត្រពាំង ។

ធម្មតាប្រពន្ធ បានដោយសិល្ប៍មន្ត ដោយស្ទាត់កំបាំង
រកស៊ីល្បៀនភ្នែក បានវែកខ្ទះឆ្នាំង បានល្មឹកន្ទាំង
នៅខះចង្អេរ ។

បាននេះខ្វះនោះ ក្រហេតុពីព្រោះ អាពុកម្តាយជេរ
បើចូលជំនុំ មិនរម្យដូចគេ អង្គុយរេះរេរ
មិនហ៊ានហាលមុខ ។

នេះពុតអ្នកក្រ ចាំជាតំណ តជាទំនុក
ប្រយ័ត្នតំនៀល គេដៀលអាពុក កូនអើយចាំទុក
ចាំតកូនចៅ ។

រក្សាពូជពង្ស បើខ្លួនល្ងីតល្ងង់ ស្តាប់ចាស់ប្រដៅ
កុំស្អប់អ្នកប្រាជ្ញ កំខ្លាចអ្នកខ្លៅ បើមនុស្សឆោតឆៅ
កូនឯងកុំភប់ ។

កុំភ័យខ្លាចអត់ មើលអោយប្រាកដ គួរយកគួរឈប់
គួរឈានគួរឈោង តោងមើលអោយគ្រប់ កុំចេះតែងប់
មិនស្គាល់ឪម៉ែ ។

រកប្តីប្រពន្ធ អោយគិតអោយគន់ អោយមើលថ្ងូនថៃ
ត្រកូលអ្នកក្បត់ ប្រាកដតាមខ្សែ បីដូចឈើផ្លែ
មិនដែលចេះក្លាយ ។

ដូចផ្លែធំតូច ដើមក្រូចផ្លែក្រូច ដើមស្វាយផ្លែស្វាយ
ពូជស្រីចោរក្បត់ មិនអត់សាហាយ ពូជស្រីមេម៉ាយ
ពីម្តាយដល់កូន ។

រើសពូជមិនខុស ពូជសាំងនឹងប្រុស ទាំងអស់បងប្អូន
ពូជសែនមេបា ពីតាដល់ដូន ពូជល្អសុទ្ធសូន្យ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ពីដូនដល់ចៅ ។

រករូបមិនក្រ អាក្រក់ហើយស មារយាទល្អហើយខ្មៅ
ស្រីក្មេងមានខ្មាស ចាស់ចង់ប្រដៅ ប្រដូចតាមផៅ
មិនសូវខុសខាន ។

ពាក្យចាស់លោកថា ធ្វើស្រែចំការ ស្តាប់មហាសង្ក្រាន្ត
ធ្វើម្តងខុសខាត ធ្វើម្តងទៀតបាន ធ្វើតាមប្រមាណ
ប្រមើលទឹកភ្លៀង ។

រកប្តីប្រពន្ធ អោយគយអោយគន់ រើសរករូបរាង
ពូជថ្លៃល្អមយក ពូជថោកល្អមវាង រូបល្អឫកល្បែង
នាងកុំប្រសព្វ ។

ជាតិស្រីនិងប្រុស បើបានជាខុស ខុសទាល់ចាស់ងាប់
បើបានរូបល្អ កម្រមានភ័ព្វ មានខុសមិនគាប់
ដូរស្រែចំការ ។

មួយទៀតអ្នកចាំ អាពុកចំណាំ ទុកជាតម្រា
កុំយកតម្រាប់ កុំស្តាប់អាចារ្យ បើនឹងរៀបការ
កុំការប្រធូន ។

ប្រជែងវេលា ពួស្តរឆ្លើយគ្នា ប្រទប់ប្រទួន
ស្រុកជិតភូមិផង របងដោយខ្លួន អាចារ្យអាងក្បួន
ថាសុខសប្បាយ ។

កូនអើយអ្នកចាំ យូរណាស់បួនឆ្នាំ ព្រាត់ប្រាស់អន្តរាយ
ច្រើនស្លាប់ពានាក់ រស់ម្នាក់មេម៉ាយ កូនឃើញតែម្តាយ
មិនឃើញអាពុក ។

មានកាលស្លាប់ស្រី ស្លាប់ចោលកូនខ្ចី ប្តីនៅរងទុក្ខ
យកប្រពន្ធទៀត កម្រពេញមុខ កូននឹងអាពុក
បែកគ្នាខ្វាត់ខ្វាយ ។

កូនចៅស្រីៗ បើនឹងយកប្តី កុំយកពោះម៉ាយ
សូវនៅម្នាក់ឯង បន្លែងនឹងម្តាយ អាណិតរូបកាយ
ស្តាយខ្លួនក្រមុំ ។

ហៅប្រុសអភ័ព្វ ប្រពន្ធដើមស្លាប់ មានកូនតូចធំ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



យកឯងជាចុង បំរុងជាយំ ច្រើនឈ្មោះជំនុំ
ព្រួយចិត្តម៉ែឪ ។

ហៅប្រុសចិត្តពីរ ពិបាករកស៊ី រញ៉ាំរញ៉ូវ
ឯងនឿយស្ទើរស្លាប់ ផ្គាប់ចិត្តមិនត្រូវ បីប្អូនរដូវ
ខ្លួនឯងស្លាប់ទៀត ។

ចង្រៃខាងប្រុស កូនអើយចាំចុះ កុំយកខ្លួនបៀត
ស្រីណាខំយក ស្រីនោះបង់មារយាទ ប្រុសព្រួយខ្ជប់ធាតុ
ខ្ជប់គ្រប់ជាបី ។

យកទៀតជាប្អូន ព្រោះដល់ស្លាប់ខ្លួន មេម៉ាយខាងស្រី
ប្រាកដមិនខុស ប្រុសក្នុងលោកិយ ស៊ូនៅអត់ប្ដី
ស្លាប់រស់រូបមួយ ។

បើខ្លួនកំព្រា រំពឹងមឹងមា រកស៊ីមិនព្រួយ
កាន់មារយាទល្អ មិនក្រគេជួយ បងប្អូនកូនក្មួយ
រត់ចូលអោយប្រើ ។

ពោះម៉ាយមានបី កុំយកធ្វើប្ដី មិនគាប់ប្រសើរ
អាមួយស្រីលែង ស្រីគេគ្រាន់បើ ពោះម៉ាយក្លាយដើរ
អាងលែងប្រពន្ធ ។

ពោះម៉ាយទាំងអស់ កុំយកអោយសោះ ហៅប្រុសទូរជន
ទូរជាតិអប្រិយ ស្រីកើតទុក្ខធ្ងន់ ហៅមួយជំនាន់
ចំណាំមិនខុស ។

កំឡោះចាស់យូរ ចាស់ទុំគេប្ដូរ ល្មមព្រមយកចុះ
រកស៊ីមានបាន សុខសាន្តឥតឈ្លោះ ចំរើនរួមរស់
អាយុយឺនយូរ ។

កុំយកប្ដីប្អូន ថោករាសីខ្លួន រកស៊ីមិនធូរ
គេហៅឯងធំ សមហៅគេពូ ច្រើនខ្ជិលទូមូ
ម៉េះមស់នឹងល្បែង ។

វាច្រើនមើលងាយ ហៅស្ដីនិយាយ ហៅហាងហៅឯង
ខ្លួនយើងជាស្រី ស្រដីឥតក្រែង យល់គេប្អូនឯង
ឯងមើលងាយដេរ ។

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ពាក្យចាស់លោកចង　ប្តីទុកស្មើបង　ប្រពន្ធស្មើម៉ែ
មើលងាយរាល់ថ្ងៃ　ចង្រៃរាល់ខែ　រកស៊ីធ្វើស្រែ
ច្រើនខាតគ្រាប់ស្រូវ ។

គួរយកប្តីបង　ពាក្យចាស់លោកចង　ទុកប្តីស្មើឪ
ខ្លួនឯងប្រមាថ　ប្រតិបត្តិអោយត្រូវ　រាសិគង់នៅ
ទេព្រក្សរក្សា ។

ប្រពន្ធនិងប្តី　ធំស្រេចលើស្រី　គត់គង់កិរិយា
ឈ្លោះហើយច្រើនខ្សត់　ស្រីអត់លក្ខណា　ប្តីខ្ជិលឧស្សាហ៍
ព្រោះប្ញកប្រពន្ធ ។

ជាតិស្រីមានលក្ខណ៍　ទេវតាពុំនាក់　កបកើតទ្រព្យធន
ប្រទេចជេរវាយ　ចង្រៃទូរជន　ដូជាតិលើសលន់
លើសលុបលើប្រុស ។

ហៅកាឡកិណី　វាយកូនជេស្តី　មិនដឹងត្រូវខុស
បើមានភ្ញៀវមក　រីតរករឿងឈ្លោះ　អសោចសាយសុស
រង្គោះធនធាន ។

រកស្រីមារយាទខ្ពស់　ចេះខ្ទើមពាក្យឈ្លោះ　ចេះទ្រាំអត់ឃ្លាន
ចេះស្ងួតចេះកាច　ចេះខ្លាចចេះហ៊ាន　ចេះខ្មាសចេះអៀន
កាចមានប្រាជ្ញា ។

កូនចៅស្រីប្រុស　ចំណាំទុកចុះ　ទុកជាតម្រា
គួរយកតម្រាប់　គួរស្តាប់ពុទ្ធដីកា　ព្រះអង្គទេសនា
គាថាបួនបទ ។

រៀនត្រាប់អ្នកប្រាជ្ញ　បើចង់ឈ្នះកាច　យកស្ងួតសង្កត់
ចង់ឈ្នះមនុស្សខឹង　អោយប្រឹងខំអត់　វាជេរវាហត់
វាស្បថលែងខឹង ។

ចង់ឈ្នះអសុរោះ　ស្តីលេងឡេះឡោះ　កុំធ្វើជាដឹង
យើងស្តីត្រង់ណា　អោយចំត្រង់ហើង　ឃើញប្ញកយើងរឹង
ខ្លាចយើងខាងក្រោយ ។

ចង់ឈ្នះកំណាញ់　ក្រដេក្រដាញ　សុំអ្វីមិនអោយ
បើបានចំណី　ហុចវាញាយ១　តិចដោយច្រើនដោយ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ក្នុងតែវាដឹង ។

នេះមន្តព្រះពុទ្ធ ប្រាជ្ញាអោយមុត អោយគិតថ្លែងថ្លឹង
កុំកាចខុសខ្នាត កើតខាតត្បិតខឹង កូនអើយខំប្រឹង
កាន់ច្បាប់ទាំងបួន ។

កុំជួញរវល់ កុំតបតទល់ កើតទាស់គុំគួន
កូនណាកាន់បាន កូននោះសុខខ្លួន ទោសទាស់លែងជួន
លែងជួបមួយជាតិ ។

បើមនុស្សរែកទូល មកនៅចំណូល ព្រោះញាស់ធ្វើញាតិ
អោយមើលលែលក កុំយកខ្លួនបៀត វាទូលទៅទៀត
អសារឥតការ ។

ចំណីចំណុក អោយស៊ីអោយចុក អោយដោយក្តីមេត្តា
កុំអោយជឿខ្ចី ក្រែងខុសសន្យា កើតទាស់កាលណា
រើរែករត់បាត់ ។

មនុស្សគ្នានកន្លែង ខុសពីមារយាទឯង មិនប្រុងប្រយ័ត្ន
តាមទាន់តឹងទារ វាខឹងក្តៅក្តាត់ គំគួនដោយស្ងាត់
បំភ្លាត់ឯងបាន ។

ហេតុនេះគួរគិត គួរកូនពិនិត្យ ច្បាប់សុំរាប់អាន
គួរអោយសុំអោយ គួរខានអោយបាន ដ្បិតពាក្យបុរាណ
មានពីរចំណែក ។

ចងទុកជាក្បួន ចិត្តល្អក្រខ្លួន នេះពាក្យមួយប៉ែក
មួយទៀតចិត្តល្អ មិនក្រយួរពេក ឆ្នាំនេះឆ្នាំស្អែក
ក្នុងតែនឹងមាន ។

ចិត្តល្អក្រខ្លួន ចាំទុកជាក្បួន ជាក្បាលនិទាន
ឃើញអ្នកទូរគត កំសត់អត់ឃ្លាន មិនស្គាល់ពោះវៀន
ហ៊ានជឿអោយខ្ចី ។

ទៅទារមិនអោយ តឹងតឿនញយៗ ខឹងប្តឹងកើតក្តី
ខាតទាំងទ្រព្យចាស់ អស់ទាំងទ្រព្យថ្មី ស្តមគោក្របី
វរល់ក្តីខានថៃ ។

ចិត្តល្អមួយទៀត មេត្រីជាញាតិ សំដីខ្ចីស្រែ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



បានស្រូវស៊ីស្កប់ ត្រឡប់កាច់កែ រំលងឆ្នាំខែ
ដកហូតមិនបាន ។

ឯងប្តីងវាត ក្តីទាល់តែក្រ អស់ឆ្នាំងអស់ចាន
របស់ក៏ខាត របរក៏ខាន ដឹងអស់ប៉ុន្មាន
ទំរាំចាញ់ឈ្នះ ។

ទ្រព្យធនអ្វី១ ចងការជឿខ្ចី មើលមុខអោយច្បាស់
កុំចោលច្បាប់ខ្មែរ កុំភ្លេចច្បាប់ព្រះ តាមតែប្រទះ
ប្រទាញសងខាង ។

ចាំចិត្តកណ្តាល បើនឹងឈឺឆ្អាល សប្បុរសមើលយ៉ាង
រៀនសួតរៀនប្រាជ្ញ កាចកុំក្អេងក្អាង ក្រែងគ្រោះសំណាង
ខ្មោចខាងវាស្អប់ ។

ល្អមិនក្រយូរ ស្វែងរៀនរកគ្រូ ស៊ូកុំស្តាយទ្រព្យ
គ្រូវាយកុំខឹង អោយប្រឹងខំផ្ចាប់ ចេះមន្តសាយសព្វ
ត្រឡប់ជាមាន ។

ធម្មតាអ្នកចេះ អ្នកស្វែងចំណេះ ចេះដ្បិតខំរៀន
ឆ្លាក់គូរក្បូរក្បាច់ សាច់សិល្បរបៀន អ្នកខ្សត់អត់ឃ្លាន
ព្រោះចិត្តអាក្រក់ ។

ខូចខិលល្ងង់ខ្លៅ គ្រូដេរប្រដៅ ខឹងលបសំឡក់
របេញរបុញ ភូតភរកុហក ស៊ូប្លន់លួចឆក់
មិនខំធ្វើស្រែ ។

អ្នកប្លន់អ្នកលួច ឆក់បានតិចតួច បានគ្រាន់បើដែរ
ដល់គេឃើញមុខ ត្រូវគុកច្រើនខែ អាក្រក់ដល់ម៉ែ
ខូចកេរ្តិ៍ដល់ឪ ។

ចង់ខ្ពស់បានទាប ចចើងចង់លោភ រែងបាត់ធនទៅ
ពាក្យពីបុរាណ លោកអានដំរូវ ឬកមនុស្សឥឡូវ
ត្រូវតាមតម្រាយ ។

អ្នកលួចអ្នកប្លន់ ចង់បានប្រពន្ធ ចេញជួញស្រុកឆ្ងាយ
ទិញងាររមេស្រុក ស្លូកធ្វើចៅហ្វាយ ចង់ថ្កើងសប្បាយ
ចាយប្រាក់រាជការ ។

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ឆបាំងបំបាត់ លួចបានអោយស្ងាត់ អាចមានប្រាជ្ញា
ក្រឡេចផ្ទាំងដៃ កាឡៃបោះត្រា ទាស់ភ្នែកទេវតា
រក្សាផែនដី ។

មួយទៀតទូរជន ធ្វើបាបបានបុណ្យ គឺបុណ្យមន្ត្រី
ទោសទៅចង់ចាប់ កាប់ឥតប្រណី បានបុណ្យមន្ត្រី
ព្រោះបុណ្យធ្វើបាប ។

អំពើរទាំងអស់ កុំសាងអោយសោះ ចៀសវាងដរាប
កាន់សីលព្រះពុទ្ធ ឱនលុតឱនក្រាប បើក្រដុនដាប
មានទេវតាជួយ ។

កូនអើយទេវតា ស្ថិតសព្វព្រឹក្សា រងោករងួយ
មនុស្សទ្រុស្តប្ញស្សា ឯណាទីមួយ ទេវតាពុំជួយ
ចំណាំស្គាល់មុខ ។

មិនដែលកំបាំង រាជការបារាំង គេចាប់ដាក់គុក
ដល់ខ្លួនស្លាប់ទៅ នៅរងសោយទុក្ខ សោយទោសនរក
ទាំងពីរកន្លែង ។

នរកបារាំង មានខ្សែយមានខ្លាំង មានខ្លីមានវែង
នរកយម្ពបាល គេផ្ទាលឥតក្រែង ព្រះអង្គសំដែង
ថាលានកោដិឆ្នាំ ។

ហេតុនេះគួរវាង គួរចោលគួររាង គួរចងគួរចាំ
គួរកុំធ្វើបាប ដរាបខ្លាចកម្ម គួរកាន់សីលប្រាំ
បណ្តាំសាសនា ។

ហៃកូនចៅអើយ ក្រឡាប់អស់ហើយ មិនដូចដូនតា
ភ្លៀងជនខែប្រាំង រាំងខែវស្សា ឆ្នាំវិករកា
ត្រីស័កនេះឯង ។

រនោចផល្លុន រកាពីមុន ឯកស័កជាក់ស្តែង
ក្នុងខ្មែតផល្លុន ជន់គ្រប់កន្លែង ទាំងគេទាំងឯង
ធ្វើស្រែបានផល ។

ឆ្នាំរោងឆស័ក វិសាខភ្លៀងធ្លាក់ ពីររោចសំគាល់
យប់ថ្ងៃអាទិត្យ ងងឹតព្យុះខ្យល់ ភ្លៀងជន់ពេញថ្នល់

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ពេញវាលធំតូច ។

ពេញអូរពេញជ្រោះ ដើមឈើទាបខ្ពស់ រលុះរលំ
ឫស្សីស្រុកយើង រលើងទាំងគុម្ព ទើបគ្រាប់វាផ្ទុំ
ផ្ដួចដុះជាថ្មី ។

ឆ្នាំចរកុរជូត រាំងរីងរហូត គ្រប់ឆ្នាំទាំងបី
កើតទាំងជម្ងឺ ស្លាប់មនុស្សប្រុសស្រី ខាលថោះអស់ភ័យ
ធ្វើស្រែស្រូវបាន ។

ភ្លៀងឆ្នាំម្សាញ់ រលីងក្បាលក្រាញ់ ត្រូវតាមបុរាណ
កក្កិកជនវាល វាលសព្វស្មសាន អ្នកស៊ឹងប៉ុន្មាន
រលួយស្រូវអស់ ។

ដាច់ថ្នល់ខានដើរ រាជការគេប្រើ ទាំងចាស់កំឡោះ
មមែរវងកម្ម បញ្ចាំកើ្កកោះ គ្មានអ្វីស៊ីសោះ
ដាច់ពោះក្សិណក្ស័យ ។

ខែចេត្រឆ្នាំរក ស្រូវឡះពពក កើតមានសម័យ
ជាហេតុអស្ចារ្យ សុរិយាល្ងាចថ្ងៃ ឧត្បាតចង្រៃ
ឃើញសត្វអ្វីហោះ ។

ពិជើងទៅត្បូង ចាស់ក្មេងមើលច្រូង បានឃើញទាំងអស់
មើលមិនស្គាល់ជាក់ ធ្លាក់ចំចន្លោះ បាត់ឈឹងសូន្យសោះ
មិនដឹងទៅឯណា ។

កាលមុននោះមក ខែបុស្សឆ្នាំរក លែងមានប្រាជ្ញា
មានតែមេស្រុក វាស់បែងក្រឡា ដីមួយហិតតា
ត្រូវសែសិបថាំង ។

រង្វាន់មេស្រុក ត្រូវហូតមួយទុក ដប់ជូនបារាំង
ទៅដល់ប៉ិុយរ៉ូ បង្ខូរដាក់ឃ្លាំង ពូជពីកន្ដាំង
ក៏ជាប់ពន្ធដែរ ។

គ្មានធូរគ្មានតឹង កូនអើយខំប្រឹង ជាតិឯងជាខ្មែរ
ក្មេងប្រុសជំទង់ នៅក្នុងឪម៉ែ រាជការប្រិតប្រែ
ថាអោយបង់ប្រាក់ ។

កូនចៅប្រុសស្រី កើតមកលើដី ខំរកលុយកាក់

CamBoWeb.com CamBoTours.com CamBoHotel.com CamBoBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



បានហើយខំប្រឹង ផ្សំគ្នាទុកដាក់ គ្រាន់ទិញស្បៀកពាក់
បង់ថ្លៃរាជការ ។

ភទ្របទឆ្នាំច ចាប់គោខ្មៅស ដុតដែកបោះត្រា
ដល់កុរជូតឆ្លូវ ដំរូវយ៉ាងណា នឹងកើតអស្ចារ្យ
របូតរាល់ឆ្នាំ ។

នគរថ្កើងប្លែក សប្បាយតែភ្នែក ក្នុងចិត្តវេទកម្ម
កូនប្រុសបណ្តាំ កុំភ្លេចបណ្តាំ កប្បាសសូត្រថ្នាំ
ត្រីមាំលែងថោក ។

ដូងស្លាអំពៅ អំបិលស្លស្រូវ មានទៅមានមក
មានចុះមានឡើង រាស្រ្តយើងល្មមរក ល្មមរ លែលក
គួរយកគួរខាន ។

កប្បាសនឹងថ្នាំ គួរដាស់គួរដាំ ធ្វើដែងឯងបាន
កុំអាងខ្ជិលពេក កុំដេកឈប់ខាន កុំចោលបុរាណ
ម៉ែឪជូនតា ។

ដីគេគរគោក កំអាងខ្ជិលដោក ទៅល្ហោកចិនផ្សារ
កូនចៅស្រី១ ខំរៀនធ្វើការ បើគ្មានប្រាជ្ញា
មានមាត់ចេះស្តី ។

អោយសួរចាស់១ រៀនបោះកប្បាស ថ្លៃចម្ងូរសំឡី
រៀនកូតរៀនការ ត្រសាវពាត់រវៃ ហូលគោមគាតក្តី
កុំបីចន្លោះ ។

រៀនផ្ការៀនត្បាញ អោយចាស់បង្ហាញ បង្ហាត់ទាំងអស់
សំពត់បែបងាយ លាយសូត្រអម្បោះ កុំទិញគេសោះ
ឈ្មោះការជាស្រី ។

ទិញដូរតែលាក់ អញ្ចុលចេសចាក់ ព្រហូតជាបី
ធ្វេញឈើឈ្នាន់ផ្សំ ក្ការមូរក្ការកី ត្រល់ខ្នារឫស្សី
មុខប្តីជាប្រុស ។

តាំងពីឆ្នាំច ការអ្វីក្រ១ ខំរៀនទៅចុះ
ទាន់មានចាស់នៅ ស្គាល់ត្រូវស្គាល់ខុស ចាស់ស្លាប់រលស់
គ្មានមនុស្សចេះដឹង ។

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



រកស៊ីអោយញ៉ឹក ដេកយប់រលឹក រឹតក្បិនអោយតឹង
បើភ្ញាក់កាលណា កាន់ការកាលនឹង កូនអើយខំប្រឹង
ទាំងប្រុសទាំងស្រី ។

រមៀតស្លឹកគ្រៃ ដីរម្មេសខ្ចីមខ្ចី មានដីដាំចុះ
ដាំដើមអ្វីៗ ចំណីគ្រប់ឈ្មោះ គ្រឿងស៊ីឆ្អែតពោះ
ជុះចោលទទេ ។

ជុះទិសខាងជើង ជុះដាក់ដីយើង កុំជុះដីគេ
កុំជុះដាក់ផ្លូវ ត្រូវមាត់ក្មេងជេរ ដីសល់ទំនេរ
ល្មមរមាត់ជុះទៅ ។

សក់មួយជាដប់ ជ្រៀតសិតអោយសព្វ កុំអោយសល់នៅ
បើប្រាជ្ញារាក់ ចាក់ចិត្តអោយជ្រៅ ដាំចេកអំពៅ
ដូរស្រូវអង្ករ ។

កើតមកជាមនុស្ស មួយព្រួយចង់រស់ មួយព្រួយចង់ល្អ
ពីនេះជាធំ វានាំអោយក្រ ចាំជាតំណ
តជាទំនុក ។

មនុស្សមារយាទមិនប៉ិន កូននៅខ្ញុំចិន ព្រោះម្ដាយឪពុក
ធ្វើស្រែមិនត្រូវ គ្មានស្រូវជង្រុក កូនអើយចាំទុក
នេះមុខមេក្រ ។

មេៗជាធំ កំឡោះក្រមុំ ស្លៀកពាក់ចង់ល្អ
បើបានបែបខ្មៅ ថានៅបែបស ទើបគ្រាន់អន់ក្រ
ត្រដរចង់ថ្កើង ។

ក្រឡាប់នគរ រឹងរឹតកើតចោរ ច្រើនឡើងច្រើនឡើង
ពាលរឹងក្រអឺត ចើតម៉ើតចើតម៉ឹង ក្រដាសយ៉ាងស្ដើង
ចាយរហែកនៅដៃ ។

ប្រាក់ចាយអស់ទៅ ព្រោះមនុស្សឥឡូវ ឧត្បាតចង្រៃ
ជាតិខ្មែរប្រែភេទ ក្រឡែតក្រឡៃ ក្រឡាស់សាសន៍សៃយ
សព្វសត្វនានា ។

ជាតិខ្មែរប្រែខុស ស្រីខ្លែងធ្វើប្រុស ប្រុសក្លែងធ្វើថ្នា
យកប្ដីប្រពន្ធ មិនស្គាល់មីងមា បុណ្យទានការងារ

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



កាប់គ្នាឥតក្រែង ។

ល្ងង់ឫកធ្វើចេះ គោចងត្រដោកសេះ ប្រុស១ដុះស្នែង
ស្រីពាក់អាវខ្លី ប្រុសពាក់អាវវែង សារុងហៀរកែង
ធ្វើឯងអ្នកគ្រាន់ ។

កាន់ចិត្តសីហលោ សេះទឹមនឹងគោ ចាក់ហ៊ោលាន់១
រកស៊ីមួយថ្ងៃ ចង់បានមួយពាន់ បរគោជល់មាន់
ចាក់កាប់ជាប់គុក ។

វិល្បែងបៀប៉ោ ច្រើនទៅជាចោរ ប្រកាសហាមទុក
ចូរកូនប្រយ័ត្ន ប្រយោជន៍ទៅមុខ ចាំជាទំនុក
តំណកូនចៅ ។

អ្នកកុំប្រហែស រាជការនិរទេស កំចាត់ចេញទៅ
រាជការអាណិត ខំប្រិតប្រដៅ កុំលោភល្ងង់ខ្លៅ
ថោកផៅត្រកូល ។

ប្រយ័ត្នក្រែងក្រ ផ្លូវច្បាប់ល្អ១ អ្នកខំប្រមូល
ផ្លូវវៀចអាក្រក់ អ្នកកុំដើរចូល ហៅផ្លូវមិនស្រួល
លង់ផុតគំនិត ។

ដើរផ្លូវកណ្តាល ស្រឡាញ់ស្និទ្ធស្នាល ឈឺឆ្អាលដោយពិត
មគ្គផលសីលទាន ឈានចូលអោយជិត យកធម៌ជាមិត្ត
មិនឥតអំពើ ។

មនុស្សម្នាក់ច្រើនឆោត ច្រើនគ្មានគេកោត ឈឺគ្មានគេមើល
ស្លាប់ឥតគេព្រួយ គេជួយទាំងស្ទើរ មិនដែលឡើងលើ
ច្រមុះចុះក្រោម ។

កូនចៅស្រី១ ក្រមុំសាវខ្ចី រៀនឆោតអោយល្មម
ប្រុសស្ទើរម៉ែឪ ឆ្នូវឆប្រលោម មើលរូបមើលឆោម
កុំព្រមដោយងាយ ។

កុំក្តិចក្តក់ក្តាញ់ បើចិត្តស្រឡាញ់ កុំចេញនិយាយ
បើស្អប់កុំប្តឹង បើខឹងកុំធ្លាយ កុំរោះកុំរាយ
កុំងាយធ្វើស្និទ្ធ ។

កុំដើរប្រាប់គេ កុំអាងអួតដេរ ក្រែងប្រុសឈឺចិត្ត

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



នៅអោយតែនឹង    កុំរវល់ធ្វើស្និទ្ធ    ប្រុសនឹងអាណិត
គិតចូលដណ្ដឹង ។

បើម៉ែឪអោយ    មើលមុខមើលក្រោយ    អាក្រក់ខ្មៅឆ្អឹង
ប្រកែកដោយស្វាត់    កុំខ្លាចម្ដាយខឹង    កើតកូនមកតឹង
ពិបាកចាយណាស់ ។

កុំឃ្លានចំណី    កុំខ្លាចអត់ប្ដី    កុំភ័យខ្លាចចាស់
មើលមុខឯងផង    កុំរើសឥតខ្មាស    ខ្លួនល្អស្រឡះ
មិនខ្វះគេស្ដី ។

បើបានជាខូច    ទាន់ដើមនៅតូច    ខែពីរខែបី
រវៀសឆ្លើយប្រញាប់    ប្រាប់គ្នាស្រីៗ    កុំលាក់ធ្វើអ្វី
ក្នុងតែគេដឹង ។

កុំមាយាបេះក្រូច    មារយាទចេះតែខូច    មាត់ចេះតែខឹង
គេថាត្រង់ណា    ដេរគេត្រង់ហ្នឹង    ដេរហើយខំប្រឹង
យកថ្មសង្កត់ ។

រំលាយរំលូត    អាក្រក់តែតួទ    អួតល្អតែមាត់
មានគេឃើញច្បាស់    ម្នះរឹងហ៊ានស្បថ    ទោសនេះនឹងភ្លាត់
ធ្លាក់ទៅអវិចី ។

ចោរកាចលួងខ្លៅ    ប្រាជ្ញប្រាមប្រដៅ    ហៅបារាជិកស្រី
មេបាកាច់គេ    ស្លាប់ពីស្លាប់បី    រំលូតកូនខ្ចី
ស្មើរំលាយព្រះ ។

មានកាលមិនក្សយ    ខ្វិនជើងខ្វិនដៃ    កខ្វេះកខ្វាស
ខ្វាក់ភ្នែកអន្ធការ    អនិច្ចារូបណាស់    អាក្រក់កើតខ្វាស
តកូនតចៅ ។

អសោចសុសសាយ    សុសសព្វដល់ម្ដាយ    ដល់ពូជពង្សផៅ
ស្លាប់ទៅរងទុក    នរកឋានក្រៅ    គេស្រុសទឹកក្ដៅ
ស្លាប់ទៅរស់ឡើត ។

ស៊ីខ្ទុះឈាមឯង    ព្រះអង្គសម្ដែង    ថាម៉ឺនសែនជាតិ
ឡើងមកជាប្រែត    ហេតុកម្មមិនឃ្លាត    អត់ឃ្លានគ្មានញាតិ
ហែកកូនឯងស៊ី ។

ព្រះពុទ្ធលែងប្រោស    ធម៌លែងសន្ដោស    សោយទុក្ខវក់វី

CamboWeb.com CamboTours.com CamboHotel.com CamboBank.com CamKoHotel

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ហេតុចិត្តឫស្យា មិច្ឆាទិដ្ឋិ កើតជាជ្រូកញី
គេត្រៀវគេចាក់ ។

អសង្ខេយ្យឆ្នាំ ហេតុផលសេសកម្ម កើតជាមនុស្សខ្វាក់
មនុស្សខ្វិនទ្រេមទ្រម ជាគមជាគាក់ ខ្ទើយឆ្កួតអបលក្ខណ៍
ជាអ្នកឥតប្តី ។

បើម្តាយជួយព្រួត ជួយជាន់រំលូត រំលាយកូនខ្ចី
នរកប្រេតព្រមគ្នា មិនឃើញរស្មី ដ្បិតចិត្តតិរ្ថិយ
ទាំងម្តាយទាំងកូន ។

ហេតុនេះគួរខ្លាច ធម្មតាចោរកាច មិនដែលស្ងាត់សូន្យ
អសោចកេរ្តិ៍ឈ្មោះ ទាំងអស់បងប្អូន មេបាតាដូន
កាត់កាលលែងរាប់ ។

គួរប្រុងឥរិយា កើតទាន់សាសនា ហៅមហាមានភ័ព្វ
ទាំងប្រុសទាំងស្រី កុំបីអោយធ្លាប់ គួរខំរៀនផ្តាប់
បរលោកលោកិយ ។

ឯខុសនិងគាប់ បើនឹងរៀបរាប់ រាល់រូបប្រុសស្រី
គាប់ខុសនៅចិត្ត ខុសគាប់នៅស្តី គំរប់ជាបី
ខុសត្រូវនៅកាយ ។

កូនប្រុងប្រព្រឹត្ត ការកេរ្តិ៍អោយជិត គំនិតអោយឆ្ងាយ
កើតមកជាខ្មែរ កុំប្រែក្លែងក្លាយ ធម្មតាសប្បាយ
វាតែងអោយទុក្ខ ។

អោយទោសទាស់ទែង ទាស់តែម្នាក់ឯង ដល់ម្តាយឪពុក
រីឯរឿងទោស មានតែពីរមុខ មួយទៅនរក
មួយនាលោកិយ ។

លោភោទោសោ កើតពីរមោហោ រាល់រូបប្រុសស្រី
គួរកាន់មេត្តា កតញ្ញូខន្តី នេះគឺបាលី
ទៅកាន់បរលោក ។

ពាក្យពិតប្រដៅ អោយអស់កូនចៅ ប្រព្រឹត្តរៀនយក
កូនណាមិនរៀន កូននឹងមារយាទថោក នឹងធ្លាក់ជ្រុលជ្រក
ក្នុងចតុរាបាយ ។

ធំស្រេចនៅស្លូត សុខខ្លួនរហូត ដរាបវែងឆ្ងាយ

AngkorPost.com AngkorDaily.com AZCambodia.com ANZCambodia.com ABCKhmer.com



ខន្តិអំណត់ សង្កត់ក្នុងកាយ ជាតិជនទាំងឡាយ
កម្រកាន់បាន ។

ចេះហើយមិនដឹង ចិត្តនៅម្នះរឹង ប្រឹងរកកម្មដ្ឋាន
រកធម៌មិនយល់ ខ្ជិលខ្វល់ឈប់ខាន បន្ទោសបុរាណ
ថាគ្មាននិស្ស័យ

វិបាបនិងបុណ្យ មានចិត្តជាមុន មាត់ជាបច្ច័យ
នាំចុលនាំឡើង ពីជើងពីដៃ សន្ទរំសព្វថ្ងៃ
ឈ្មោះហៅសំណាង ។

កើតក្នុងលោកិយ រាល់រូបប្រុសស្រី មានចិត្តជាអាង
កុសលអកុសល ប្រទាញសងខាង រូបនៅតែងតាង
តែងតាមទៅមក ។

មគ្គផលសីលទាន បើល្ងង់អោយរៀន បើគ្មានអោយរក
យល់ល្អសាងស្អាត សង្វាតជ្រៀតជ្រក ជ្រែកសរើសរៀនយក
រក្សារូបកាយ ។

នេះគឺហៅច្បាប់ ជាទីសណ្ដាប់ សណ្ដានទាំងឡាយ
កូនចៅប្រុសស្រី កុំបីនឿយណាយ សង្ខេបបរិយាយ
និដ្ឋិតំតែងចប់ ។

អ្នកព្រះភិរម្យ អាចារ្យង៉ុយខ្ញុំ បង្គំម្រាមដប់
លើសលស់ឆ្កាំឆ្គង រំលងពុំគាប់ ពុំគួរសមសព្វ
សុសសាយសេចក្ដី ។

កាយកម្មវចីកម្ម ឈ្មោះច្បាប់បណ្ដាំ កូនចៅប្រុសស្រី
ជាបរមត្ថក្រៅ មិនហៅបាលី បរលោកលោកិយ
ទាំងពីរកន្លែង ។

បើលោកឯណា ចេះចាំធម៌អាថ៌ ប្រាកដជាក់ស្ដែង
ឃើញខុសត្រង់ណា កុំថាជាល្បែង ត្បិតពាក្យខ្ញុំតែង
អោយក្មេងវាភ័យ ។

មិនមែនភរភូត កុំថាខ្ញុំអួត ប្រាជ្ញាខ្ញុំវៃ
ឃើញមនុស្សវង្វេង ខ្ញុំតែងច្បាប់ថ្មី អស់អាថ៌សេចក្ដី
ឯវិចប់ហោង ។

អ្នកព្រះភិរម្យភាសា **អ៊ូ** ហៅ **ង៉ុយ**